ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខ: ០០៣/២៦ ក.ប/ស.ជ.ណ.ខ.ល

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផាកពិន័យចំពោះសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលតម្រូវឱ្យបងប្អូនអតីតពលករខ្មែរត្រឡប់មកពីថៃត្រូវតែផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការដាក់ពាក្យធ្វើការ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមក្រើនរំលឹកដល់ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រទាំងអស់ឱ្យបានជ្រាបថា ក្រសួងនឹងចាត់វិធានការផាកពិន័យចំពោះម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រដែលតម្រូវឱ្យបងប្អូនអតីតពលករខ្មែរដែលត្រឡប់មកពីថៃត្រូវតែផ្តល់នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការដាក់ពាក្យធ្វើការ។ ការទាមទារនេះ ជាការអនុវត្តផ្ទុយនឹងខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ០២៦/២៥ ក.ប/ស.ជ.ណ.ខ.ល ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៥ ស្តីពីការលើកលែងលក្ខខណ្ឌតម្រូវឱ្យភ្ជាប់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរក្នុងការដាក់ពាក្យធ្វើការចំពោះបងប្អូនពលករខ្មែរដែលត្រឡប់មកពីប្រទេសថៃ ហើយត្រូវចាត់ទុកជាការបំពានលើចំណាត់ការរបស់អធិការការងារដោយប្រឈមនឹងការផាកពិន័យជាប្រាក់ស្របតាមច្បាប់ស្តីពីការងារ។

ក្រសួងសូមបញ្ជាក់ថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រ អាចប្រើប្រាស់សំបុត្របញ្ជាក់កំណើត ឬសៀវភៅគ្រួសារ ឬលិខិតឆ្លងដែន ឬលិខិតធ្វើដំណើរពលករកម្ពុជាធ្វើការនៅបរទេស (លិខិតធ្វើដំណើរ TD) ឬប័ណ្ណព្រំដែនកម្ពុជា-ថៃ ឬលិខិតបញ្ជាក់អត្តសញ្ញាណដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការស្នើសុំធ្វើសៀវភៅការងារកម្មករនិយោជិតខ្មែរ និងការចុះបញ្ជី ប.ស.ស. សម្រាប់បងប្អូនពលករខ្មែរដែលត្រឡប់មកពីថៃ។

ក្នុងករណី សាធារណជនបានដឹងអំពីការដាក់លក្ខខណ្ឌតម្រូវឱ្យយកតែអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការដាក់ពាក្យធ្វើការចំពោះបងប្អូនអតីតពលករខ្មែរដែលត្រឡប់មកពីថៃ សូមប្តឹងមកអធិការការងារតាមរយៈប្រព័ន្ធទាន់ហេតុការណ៍លេខ "១២៨៦" ឬ "១២៩៧" ឬប្រអប់បណ្តឹងអនាមិករបស់ក្រសួង https://feedback.mlvt.gov.kh/feedback ដើម្បីក្រសួងចាត់វិធានការតាមច្បាប់ជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស ក្រុមហ៊ុន រោងចក្រទាំងអស់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាព។

ថ្ងៃអាទិត្យ ៧កើត ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមករា ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ហេង សួរ

"បណ្តឹងអនាមិក"

ចម្លងជូន:
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា
- សហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា
- សមាគមវាយនភណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា